# មេរៀនទី ១១៧: ព្រះយេស៊ូវប្រទានពរដល់ក្មេងៗ

## ម៉ាកុស ១០:១៣-១៦

**គោលបំណង៖** ព្រះយេស៊ូវស្រលាញ់ក្មេងៗ។

**ខគម្ពីរចងចាំ៖ ម៉ាកុស ១០:១៤ខ** *"ទុកឲ្យកូនក្មេងមកឯខ្ញុំចុះ កុំឃាត់វាឡើយ ដ្បិតនគរព្រះមានសុទ្ធតែមនុស្ស ដូចវារាល់គ្នាដែរ។"*

**ការថ្វាយបង្គំសំរាប់គ្រូ៖ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន)**

ព្រះយេស៊ូវគឺជាព្រះដ៏មានព្រះចេស្តា ជាព្រះដែលបង្កើតលោកីយ៍ និងឈ្នះសេចក្តីស្លាប់ ទ្រង់យកចិត្តទុកដាក់ចំពោះទារកទាំងអស់ កុមារទាំងអស់ យុវជនទាំងអស់ និងមនុស្សគ្រប់វ័យទាំងអស់។ មនុស្សពូកែតែងតែសេពគប់តែជាមួយមនុស្សពូកែដូចគ្នាប៉ុណ្ណោះ - ពួកគេមិនចង់ខ្ជះខ្ជាយពេលវេលារបស់ពួកគេលើមនុស្សដែលនឹងមិនជួយពួកគេទេ។ ប៉ុន្តែព្រះយេស៊ូវគឺខុសគ្នា! ព្រះយេស៊ូវមានចិត្តស្រឡាញ់ចំពោះអ្នក ហើយចង់ចងមិត្តភាពជាមួយនឹងអ្នក។ ទ្រង់ស្រឡាញ់មនុស្សគ្រប់គ្នាដូចៗគ្នា។ តើអ្នកអាចស្រមៃពីជម្រៅនៃសេចក្តីស្រឡាញ់របស់ព្រះគ្រីស្ទចំពោះអ្នកបានទេ? សូមអានព្រះគម្ពីរ **រ៉ូម ៨:៣៨-៣៩** ហើយរំឭកខ្លួនអ្នកអំពីសេចក្តីស្រឡាញ់របស់ព្រះអង្គសង្គ្រោះចំពោះអ្នក។ រួចគិតអំពីសំណួរនេះ៖ តើអ្នកបានធ្វើតាមគំរូរបស់ព្រះអម្ចាស់ទេ? តើអ្នកអាចស្រឡាញ់នរណាម្នាក់ ដោយប្រើសេចក្តីស្រឡាញ់របស់ព្រះយេស៊ូវបានទេ?

**ចំរៀង៖** ១.ក្តីស្រឡាញ់នៃព្រះផ្អែមហើយអស្ចារ្យ ២.ព្រះយេស៊ូវស្រឡាញ់កុមារណាស់ ៣.ព្រះយេស៊ូវស្រឡាញ់ខ្ញុំណាស់

**១. អធិស្ឋាន** *(សូមនាំកុមារអធិស្ឋានបើក)*

**២. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

**៣. ល្បែងកំសាន្ត «គ្រួសារក្នុងព្រះគ្រីស្ទ»**

**សម្ភារៈដែលត្រូវការ៖** ក្រមា



១. ចែកកុមារជា២-៣ក្រុម ហើយឲ្យក្រមាទៅក្រុមនីមួយៗ

២. គោលបំណងនៃល្បែងនេះគឺ ដើម្បីធ្វើឱ្យប្រាកដថាកុមារគ្រប់គ្នាឈរនៅលើក្រមាដោយមិនប៉ះដី។



៣.នៅពេលដែលគ្រូប្រាប់ការណែនាំក្រុមនីមួយៗ ត្រូវបត់ក្រមានោះពាក់កណ្តាល។ បន្តបត់ក្រមានោះពាក់កណ្តាលរហូតដល់ក្រមានោះតូចជាងមុន កុមារត្រូវតោងគ្នាឱ្យជាប់ ធ្វើយ៉ាងណាដើម្បីកុំឲ្យប៉ះដី។

៤.ក្រុមណាដែលអាចឈរនៅលើក្រមានោះបានទាំងអស់គ្នាដោយមិនប៉ះដី នោះក្រុមរបស់ពួកគេនឹងឈ្នះល្បែងនេះ។

៥. បន្ទាប់ពីលេងល្បែងនេះចប់សូមពន្យល់កុមារថា យើងត្រូវជួយគ្នាទៅវិញទៅមក ដើម្បីយើងទាំងអស់គ្នាអាចរៀនពីសេចក្តីស្រឡាញ់របស់ព្រះវរបិតានៃយើង។ ព្រះស្រឡាញ់កុមារហើយយើងត្រូវប្រាប់អ្នកដទៃអំពីសេចក្តីស្រលាញ់នោះដែរ!

## ៤. ការណែនាំមេរៀន

តើនរណាជាមនុស្សសំខាន់ជាងគេនៅក្នុងប្រទេសកម្ពុជា? តើនរណាដែលសំខាន់ជាងគេនៅក្នុងភូមិរបស់ប្អូន នៅក្នុងក្រុមគ្រួសាររបស់ប្អូន និងនៅក្នុងសាលារបស់ប្អូន? ហេតុអ្វីបានជាពួកគេសំខាន់? មនុស្សគឺខ្វល់ខ្វាយតែពីបុគ្គលដែលសំខាន់តែប៉ុណ្ណោះ។ តើព្រះស្រលាញ់តែអ្នកដែលសំខាន់មែនដែរឬទេ? អត់ទេ! ព្រះគឺស្រលាញ់មនុស្សគ្រប់គ្នាសូម្បីតែក្មេងៗផងដែរ! ថ្ងៃនេះយើងនឹងរៀនអំពីព្រះយេស៊ូវ ដែលទ្រង់បានបង្ហាញសេចក្តីស្រលាញ់របស់ទ្រង់ចំពោះក្មេងៗ។

## ៥. រឿងនៅក្នុងព្រះគម្ពីរ

ព្រះយេស៊ូវគឺជាបុគ្គលដ៏សំខាន់នៅក្នុងជំនាន់ព្រះគម្ពីរសញ្ញាថ្មី។ មនុស្សគ្រប់គ្នាចង់ជួបទ្រង់ និងរៀនសូត្រពីព្រះអង្គ។ ពួកគេក៏ចង់ឲ្យព្រះអង្គប្រទានពរ និងព្យាបាលដល់ពួកគេដែរ។ មានការអស្ចារ្យជាច្រើនដែលព្រះយេស៊ូវបានធ្វើ ហើយក៏មានមនុស្សជាច្រើនបានមកជួបទ្រង់ផងដែរ។

ពេលមួយដែលព្រះយេស៊ូវកំពុងតែរវល់ក្នុងការបង្រៀន មានឪពុកម្តាយរបស់ក្មេងខ្លះចង់ឲ្យព្រះយេស៊ូវប្រទានពរដល់កូនៗរបស់ពួកគាត់។ ប៉ុន្តែពួកសិស្សរបស់ព្រះយេស៊ូវគិតថា ព្រះយេស៊ូវកំពុងរវល់ ដូច្នេះពួកគេបានប្រាប់ទៅឪពុកម្តាយឲ្យនាំក្មេងៗត្រឡប់ទៅវិញ។ នៅពេលដែលព្រះយេស៊ូវបានឮថាឲ្យនាំក្មេងៗត្រឡប់ទៅវិញ នោះទ្រង់មិនសប្បាយចិត្តនោះទេ! ទ្រង់ក៏មានបន្ទូលថា **ម៉ាកុស១០:១៤ខ** “ទុកឲ្យកូនក្មេងមកឯខ្ញុំចុះ កុំឃាត់វាឡើយ ដ្បិតនគរព្រះមានសុទ្ធតែមនុស្សដូចវារាល់គ្នាដែរ។”

ពេលនោះក្មេងៗបានចូលទៅឯព្រះយេស៊ូវយ៉ាងសប្បាយរីករាយ ហើយទ្រង់ក៏លេងនិងសើចជាមួយពួកគេផងដែរ។ ព្រះគម្ពីរចែងថាព្រះយេស៊ូវបានឱបក្មេងៗនៅក្នុងព្រះហស្តទ្រង់! សាកស្រមៃពេលព្រះយេស៊ូវលើកអ្នកឡើងហើយឱបអ្នកនោះ តើអ្នកមានអារម្មណ៍ដូចម្តេច? ព្រះយេស៊ូវចង់បង្ហាញអ្នករាល់គ្នាថា ទ្រង់ស្រឡាញ់ក្មេងៗ!

ព្រះយេស៊ូវស្រលាញ់អ្នក! សម្រាប់អ្នកទ្រង់មិនដែលនិយាយពាក្យថារវល់នោះទេ ហើយទ្រង់សព្វព្រះទ័យក្នុងការចំណាយពេលជាមួយអ្នក។ អ្នកអាចរត់ទៅរកព្រះបានគ្រប់ពេលដែលអ្នកចង់ ហើយទ្រង់តែងតែប្រុងប្រៀបស្តាប់អ្នកជានិច្ច ទ្រង់នឹងឱបអ្នកក្នុងព្រះហស្តទ្រង់។ ជាការពិតព្រះយេស៊ូវចង់ឲ្យយើងរស់នៅជាមួយទ្រង់ជារៀងរហូតក្នុងនគររបស់ព្រះអង្គ។ ប៉ុន្តែមនុស្សគ្រប់គ្នាមិនបានដឹងទេថា ព្រះយេស៊ូវស្រលាញ់ក្មេងៗ! ពួកយើងគួរតែប្រាប់មិត្តភក្តិរបស់យើងថា ព្រះយេស៊ូវស្រលាញ់ពួកគេ ដូច្នេះពួកគេក៏អាចចូលក្នុងនគររបស់ព្រះជាមួយពួកយើងដែរ!

## ៦. សំនួរពិភាក្សា

១. ហេតុអ្វីបានជាមនុស្សម្នាចង់ជួបព្រះយេស៊ូវ?

*ដើម្បីរៀនពីទ្រង់ សុំព្រះពរ ការប្រោសឲ្យជា និងការអស្ចារ្យផ្សេងៗទៀត*

២. តើនរណាដែលប្រាប់ឲ្យក្មេងៗត្រឡប់ទៅវិញនោះ? *ពួកសិស្សរបស់ព្រះយេស៊ូវ*

៣. តើនរណាដែលបានខឹងនៅពេលដែលពួកសិស្សប្រាប់ឲ្យក្មេងៗត្រឡប់ទៅវិញនោះ? *ព្រះយេស៊ូវ*

៤. តើព្រះយេស៊ូវបានធ្វើដូចម្តេចនៅពេលដែលក្មេងៗមកឯទ្រង់?
*ព្រះអង្គបានឱបពួកគេដោយព្រះហស្តទ្រង់ និងបានប្រទានពរដល់ពួកគេ*

៥. តើអ្នកគួរប្រាប់អំពីព្រះយេស៊ូវដល់អ្នកណា ដើម្បីឲ្យពួកគេអាចទទួលបានសេចក្តីស្រលាញ់ពីព្រះយេស៊ូវដែរនោះ? *ទុកឲ្យកុមារជាអ្នកឆ្លើយ*

## ៧. ល្បែងកំសាន្ត «សាវ័កឃាត់ក្មេងៗមិនឲ្យមកជួបព្រះយេស៊ូវ»






១. ជ្រើសរើសកុមារពីរនាក់ ម្នាក់ដើរតួជាព្រះយេស៊ូវ និងម្នាក់ទៀតដើរតួជាសិស្សរបស់ព្រះយេស៊ូវ។

២. ព្រះយេស៊ូវត្រូវឈរនៅចុងម្ខាងនៃថ្នាក់រៀន ហើយសិស្សរបស់ព្រះ-យេស៊ូវឈរនៅប្រហែល១ម៉ែត្រពីព្រះយេស៊ូវ រួចប្រុងប្រៀបខ្លួនក្នុងការលេង "ក្រហម បៃតង"។ កុមារដែលនៅសេសសល់ត្រូវឈរនៅចុងម្ខាងទៀតនៃថ្នាក់រៀន។



៣. នៅពេលដែលគ្រូស្រែកថា "បៃតង" សិស្សរបស់ព្រះយេស៊ូវត្រូវឈរបែរមុខទៅជញ្ជាំង កុមារដែលនៅសេសសល់អាចដើរឲ្យលឿនទៅរកព្រះយេស៊ូវបាន។

៤. ប៉ុន្តែប្រសិនបើគ្រូស្រែកថា "ក្រហម" នោះសិស្សរបស់ព្រះយេស៊ូវងាកមកក្រោយ ហើយបើឃើញកុមារណាម្នាក់កម្រើកខ្លួន នោះកុមារនោះត្រូវតែអង្គុយចុះ។ នៅពេលដែលសិស្សរបស់ព្រះយេស៊ូវបែរមុខទៅរកជញ្ជាំងវិញ នោះកុមារទាំងអស់អាចបន្តផ្លាស់ទីទៅរកព្រះយេស៊ូវទៀត។ បន្តលេងល្បែងនេះរហូតដល់កុមារណាម្នាក់អាចទៅគៀកព្រះយេស៊ូវ និងប៉ះទ្រង់បាន។

៥. បន្ទាប់ពីលេងល្បែងនេះចប់សូមពន្យល់កុមារថា ព្រះយេស៊ូវគឺស្រលាញ់កុមារគ្រប់ៗគ្នា។

## ៨. ខគម្ពីរចងចាំ ម៉ាកុស ១០:១៤ខ

## ៩. ហត្ថកម្ម «ព្រះយេស៊ូវស្រលាញ់ខ្ញុំ»

**សម្ភារៈដែលត្រូវការ៖** ព្រីនក្រដាសហត្ថកម្ម

១. ឲ្យក្រដាសហត្ថកម្មទៅកុមារម្នាក់មួយ

២. ប្រាប់ឲ្យកុមារអានខគម្ពីរចងចាំទាំងអស់គ្នា ហើយគូសរូបរបស់ពួកគេ និងរូបព្រះយេស៊ូវ។

**១០. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

**១១. អធិស្ឋាន** *(សូមនាំកុមារអធិស្ឋានបិទ)*

# ព្រះយេស៊ូវស្រលាញ់ខ្ញុំ

ម៉ាកុស ១០:១៤ខ “*ទុកឲ្យកូនក្មេងមកឯខ្ញុំចុះ កុំឃាត់វាឡើយ ដ្បិតនគរព្រះមានសុទ្ធតែមនុស្សដូចវារាល់គ្នាដែរ។*”

(សូមគូសរូបរបស់ពួកគេ និងរូបព្រះយេស៊ូវ)